# អរិយធម៌ឈីមូ ( Chimu civilization)

អរិយធម៌ឈីមូ ( The Chimu Civilization ) គឺជាអរិយធម៌ដ៏សំខាន់មួយដែលបង្កើតឡើងដោយក្រុមមនុស្សមួយក្រុមនៅក្នុងតំបន់អាមេរិកខាងត្បូង ហើយអរិយធម៌នេះកើតឡើងមុនពេលការមកដល់របស់ជនជាតិអេស្ប៉ាញមកគ្រប់គ្រងតំបន់អាមេរិក និងមុនពេលនៃអរិយធម៌អ៊ីនកាកកើតឡើងទៅទៀត។

បច្ចុប្បន្នអរិយធម៌នេះស្ថិតនៅខាងជើងនៃប្រទេសប៉េរូ ហើយមានទីក្រុងឈ្មោះថា ចាន់ចាន់ (Chan Chan ) ដែលជាទីក្រុងនៃ នយោបាយ សាសនា និងវប្បធម៌ដ៏ធំនៃអរិយធម៌ឈីមូ។[១] ទីក្រុងចាន់ ចាន់នេះស្ថិតនៅក្បែរនឹងទន្លេម៉ូច ( Moche River) និងស្ថិតនៅក្បែរនឹងអរិយធម៌ម៉ូច (Moche civilization) ដែលមានចម្ងាយប្រមាណជាង៥៥០គីឡូម៉ែត្រពីរាជធានីលីម៉ានៃប្រទេសប៉េរូ ( រូបលេខ១)។ ទីក្រុងចាន់ ចាន់ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកក្នុងឆ្នាំ ១៩៨៦ ក្នុងការជួយថែរក្សា ជុសជុល និងការពារ ជាសម្បត្តិបេតិកភណ្ឌពិភពលោក។[២] តាមរយៈស្លាកស្នាមទាំងនោះ និងការសង្កេតមើលប្លង់នៃការកសាងទីក្រុងនេះ អ្នកស្រាវជ្រាវបានបង្ហាញថា ស្ថានីយនេះ គឺជាទីក្រុងដ៏ធំមួយដែលកកើតឡើងមុននៃអរិយធម៌អ៊ីនកា ( Pre Inca civilization) ឬអរិយធម៌មុនកូឡុំបូ (Pre-Columbian America)[៣] (រូបលេខ២)។

ទីក្រុងនេះ មានទំហំប្រមាណ ៣៦ម៉ែត្រការ៉េ និងជាបណ្តុំនៃសំណង់ផ្សេងៗជាច្រើនទៀត ដែលសំណង់ទាំងនោះកសាងអំពីដី ដែលរចនាសម្ព័ន្ធនៃទីក្រុងនេះ ហៅជាភាសាអង់គ្លេសថា Adobe brick structure។[៤] នៅក្នុងទីក្រុងនេះសំណង់ដែលសំខាន់ជាងគេហៅថា *ciudadelas* ឬ palaces ដែលជាសំណង់ ព្រះរាជវាំង និងសំណង់ *huacas* ដែលជាសំណង់

---

[១] https://whc.unesco.org/en/list/366/

[២] Ibid

[៣] Ibid

[៤] https://www.researchgate.net/figure/Tschudi-Palacio-Chan-Chan-Peru-Know-how-of-the-adobe-constructive-technique_fig1_279479948

អត្ថបទដោយ៖ អេង តុលា

ប្រាសាទពីរ៉ាមីត។ រចនាសម្ព័ន្ធសំណង់ Ciudadelas គឺមានទីលានជារាងការ៉េ ដែលជាកន្លែងសម្រាប់ប្រារព្ធពិធីសាសនា និងមានការឆ្លាក់ចម្លាក់ផ្សេងៗនៅតាមជញ្ជាំង។[៥] លក្ខណៈពិសេសនៃសំណង់ស្ថាបត្យកម្មនៅទីនេះ ក៏មិនខុសអ្វីពីអរិយធម៌ម៉ូចដែរ គឺជាចម្លាក់ក្រឡោតទាប និងរូបគំនូរទឹកពណ៌នៅតាមជញ្ជាំងប្រាសាទដែលជាស្នាដៃគំនូរដ៏អស្ចារ្យនេះក៏អាចនិយាយបានថាមនុស្សក្នុងអរិយធម៌ឈីមូ មានបច្ចេកទេសខ្ពស់ក្នុងការឆ្លាក់ដែលអាចរក្សាបានយូរហូតដល់សព្វថ្ងៃនេះ (រូបលេខ៣-៥ )។ ម្យ៉ាងទៀតមនុស្សនៃអរិយធម៌នេះពូកែខាងផ្នែកបច្ចេកទេសសិល្បៈ ក្នុងការកសាងសំណង់អំពីដី ដែលមានទំហំធំៗ និងមានសិល្បៈសំបូរបែបដែលសមស្របទៅនឹងវប្បធម៌អរិយធម៌របស់ខ្លួន។

អ្នកស្រាវជ្រាវក៏បានរកឃើញនូវវត្ថុសិល្បៈជាច្រើនដែលរួម គ្រឿងអលង្ការ, គ្រឿងស្មូនអំពីដី, កុលាលភាជន៍រូបសត្វជាដើម ( រូបលេខ៦-៨)។ តាមរយៈការសិក្សាលើរូបគំនូរនៅលើកុលាលភាជន៍ទាំងនោះបានបង្ហាញពីសង្គម និងមជ្ឈដ្ឋានជុំវិញនៃអរិយធម៌នេះកាលពីសម័យបុរាណដែរ ។

តាមរយៈទិន្នន័យផ្សេងៗខាងលើ អ្នកស្រាវជ្រាវបានបង្ហាញថា អរិយធម៌ឈីមូមានការរីកចម្រើន នៅអំឡុងស.វ.ទី១២ និងបញ្ចប់នៅស.វ.ទី១៥[៦] ពោលគឺចាប់ពីឆ្នាំ ១១០០នៃគ.ស. រហូតដល់ឆ្នាំ ១៤៧០ ដែលជាឆ្នាំអរិយធម៌ឈីមូស ត្រូវបានដួលរលំដោយការឈ្លានពានពីសំណាក់អរិយធម៌អ៊ីនកា ដែលត្រូវបានគេស្គាល់ជាអរិយធម៌ដ៏រុងរឿងជាងគេនៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសប៉េរូ។[៧]

---

[៥] http://www.archcalc.cnr.it/indice/PDF24/09_Colosi_et_al.pdf

[៦] https://www.britannica.com/place/Chan-Chan

[៧] Ibid




រូបលេខ១៖ ផែនទីនៃអរិយធម៌ឈីមូ

ប្រភព៖ Internet




រូបលេខ២៖ ប្លង់នៃទីក្រុងចាន់ ចាន់

ប្រភព៖ Internet



រូបលេខ៣-៥ ៖ ចម្លាក់ក្បាច់រូបសត្វនៅតាមជញ្ជាំងសំណង់នៃទីក្រុងចាន់ ចាន់

ប្រភព៖ Internet







រូបលេខ២៦-៨ ៖ គ្រឿងលោហៈធាតុ និង កុលាលភាជន៍រូបសត្វ

ប្រភព៖ https://www.artic.edu

## ឯកសារយោង

https://whc.unesco.org/en/list/366/

អត្ថបទដោយ៖ អេង តុលា

https://www.researchgate.net/figure/Tschudi-Palacio-Chan-Chan-Peru-Know-how-of-the-adobe-constructive-technique_fig1_279479948
http://www.archcalc.cnr.it/indice/PDF24/09_Colosi_et_al.pdf
https://www.britannica.com/place/Chan-Chan

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION